# ស្ថាននាម «ត្បូងរមាំង» តាមរយៈសិលាចារឹក

នៅក្នុងអត្ថបទមុន យើងស្វែងយល់រួចមកហើយអំពីអត្ថន័យនៃសិលាចារឹករកឃើញថ្មីមួយនៅប្រាសាទបន្ទាយព្រាវ ដែលមានចុះលេខសម្គាល់ K.១៤៣៣។ ដូច្នេះ យើងរំលឹកឡើងវិញបន្តិចថាអត្ថបទសិលាចារឹកនោះ និយាយអំពីដីភូមិបុកោង និងចន្ទ្រក្សេត្រ ដែលត្រូវថ្វាយដល់ប្រាសាទសិវលិង្គនៅឯត្បូងរមាំង ក្នុងឆ្នាំ៩៤៩នៃមហាសករាជ (១០២៧គ.ស.) និងរំលឹកអំពីអ្នកបម្រើប្រុសម្នាក់ឈ្មោះកន្សូរដែលចាញ់ក្ដីវាបពល ហើយត្រូវឱ្យយកទៅបម្រើនៅឯប្រាសាទសិវលិង្គ។ ចុងក្រោយជាបញ្ជីឈ្មោះខ្ញុំបម្រើប្រុស៩នាក់ (រាប់ទាំងកន្សូរ)។ សិលាចារឹកនេះ ក៏ជាសេចក្ដីបំពេញបន្ថែមលើសិលាចារឹក K.២២១ និង K.២២២ លើករណីថ្វាយខ្ញុំទៅប្រាសាទសិវលិង្គ។[1]

ស្ថាននាម «ត្បូងរមាំង» ដែលមានសំណេរបុរាណជា «ថ្បូងម្រាំង» បានបង្ហាញវត្តមាននៅក្នុងសិលាចារឹកប្រាសាទបន្ទាយព្រាវ (K.២២១: S១ & N២១) សិលាចារឹកប្រាសាទស្ដុកកក់ធំ (K.២៣៥: D៧២, D៩០ & D៩២) សិលាចារឹកប្រាសាទគោកពោធិ៍ (K.២៥៦/K.៨១៤: W៥៥) និងសិលាចារឹកប្រាសាទបឹង (K.៩៨៩: B៨ & B១៤) ។ លោក ហ្សក ហ្គ្រូលីយេរ[2] និងលោក ហ្សក សឺដេស[3] យល់ថាស្ថាននាម «ត្បូងរមាំង» នេះជាគឺឈ្មោះបុរាណរបស់ប្រាសាទបន្ទាយព្រាវ។ លោក ហ្គ្រូលីយេរ (1924) បានពន្យល់បែបនេះដោយយោងទៅលើសិលាចារឹកស្ដុកកក់ធំ ដែលរៀបរាប់ថាប្រាសាទនិងដីត្បូងរមាំង នៅខាងកើតដីអន្ទ្រើមលោង (ពាក្យបុរាណ **អន្ទ្រំលោង** K.២៣៥: D៨៩) ចំណែកឯដីស្ដុករមាំងក៏ពង្រីងរហូតមកខាងលិច យ៉ាងហោចណាស់ក៏មកដល់បន្ទាយព្រាវផងដែរ។ រីឯលោក សឺដេស ពុំបានពន្យល់អ្វីវែងឆ្ងាយអំពីសម្មតិកម្មរបស់លោកឡើយ។

មិនខុសគ្នាពីប្រាសាទព្រះគោ ប្រាសាទលលៃ និងប្រាសាទមួយចំនួនទៀតនោះ នៅប្រាសាទបន្ទាយព្រាវនេះ មានតួប្រាសាទសំខាន់បី ដែលមានសិលាចារឹកនៅលើមេ

---

[1] សូមអាន៖ https://ams.com.kh/khmercivilization/detail/8119

[2] Groslier George, 1924: p.336 យោងលើ Cambodge, II, p. 329

[3] Cœdès George,1964, p.164 យោងលើ IC, III, p. 54

អត្ថបទដោយៈ ហ៊ុន ឈុនតេង

ទ្វារ ចារអំពីតង្វាយផ្សេងៗចំពោះទេពនៃតួប្រាង្គនីមួយៗនោះ។ នៅក្នុងសិលាចារឹក K.២២១ (S១ & N២១) បានបង្ហាញថាតួប្រាសាទកណ្ដាលនោះជាប្រាសាទសិវលិង្គ ដោយបញ្ជាក់ច្បាស់ថានៅតំបន់ក្នុងត្បូងរមាំង៖ **ឱយភូមិតវ្រះកម្រតេងអញគិវលិង្គថ្បូងម្វាំង** (K.២២១: S១) = ថ្វាយភូមិដល់ព្រះគម្តែងអញសិវលិង្គ(នៅ)ត្បូងរមាំង។ ការបញ្ជាក់នេះ ដោយសារតែប្រាសាទសិវលិង្គមានច្រើនណាស់នៅក្នុងសង្គមខ្មែរកាលពីបុរាណ ដូច្នេះលុះណាតែបញ្ជាក់អំពីទីតាំងឱ្យបានច្បាស់ ដើម្បីកុំឱ្យមានការភាន់ច្រឡំ ឬក៏មានបញ្ហាចំពោះការបែងចែកផលប្រយោជន៍ណាមួយរបស់ប្រាសាទ។ យើងក៏អាចមើលជាឧទាហរណ៍មួយក្នុងចំណោមឧទាហរណ៍យ៉ាងច្រើន[៤] គឺករណីប្រាសាទឯកភ្នំ នៅខេត្តបាត់ដំបង។ សិលាចារឹកនៅប្រាសាទនោះ (K.២២១) ចាររៀបរាប់ពីព្រាហ្មណ៍យោគីស្វរបណ្ឌិតដែលជាព្រះរាជគ្រូរបស់ព្រះបាទសូរ្យវម៌្មទេវទី១ ថាលោកជាស្ថាបនិក និងបានថ្វាយតង្វាយរបស់ចំពោះប្រាសាទសិវលិង្គ នៅឯព្រះស្រីនរេន្ទ្រគ្រាម[៥] គឺប្រាសាទឯកភ្នំបច្ចុប្បន្ននេះឯង។

ឥឡូវយើងពិនិត្យមើលលើសិលាចារឹកប្រាសាទស្ដុកកក់ធំ (K.២៣៥) ដែលប្រាសាទនោះមានទីតាំងចម្ងាយប្រមាណជា១៩គីឡូម៉ែត្រ ពីប្រាសាទបន្ទាយព្រាវម្ដង។ សិលាចារឹកនេះបង្ហាញថា នៅពេលព្រះបាទឧទយាទិត្យវម៌្មទេវទី២ឡើងសោយរាជ្យ បាន៣ព្រះវស្សា ព្រះរាជគ្រូ «ជយេន្ទ្របណ្ឌិត» បានកសាងប្រាសាទសិវលិង្គនៅឯ «ភទ្រនិកេតន»(ប្រាសាទស្ដុកកក់ធំ) ទើបធ្វោញមាធវៈដែលជាអ្នកបានរួមគ្នាជាមួយព្រាហ្មណ៍សង្កស់ទិញដីចាត់ចែងរៀបចំជាចំណត[៦] ហើយគាត់ក៏ជាអ្នកគ្រប់គ្រងនៅប្រាសាទសិវលិង្គអន្ទើមលោងដែរនោះ បានទូលថ្វាយសុំព្រះអង្គឱ្យប្រទានចំណត ដី ខ្ញុំបម្រើទាំងឡាយនោះឱ្យជារណ្ដាប់បូជាចំពោះប្រាសាទសិវលិង្គភទ្រនិកេតន។ បន្ទាប់មកជាការរៀបរាប់អំពីព្រំប្រទល់ដីអន្ទើម

---

[៤] មានសិលាចារឹកដទៃទៀតដែលបញ្ជាក់អំពីរឿងបែបនេះដូចជា៖ ព្រះសិវលិង្គស្រុកថ្មបាយ, ព្រះសិវលិង្គស្រុកទទឹង, ព្រះសិវលិង្គស្រុកស្រូ---(K.១៧៥: N២-៣); គម្តែងជគត(នៅឯ)ភទ្រនិកេតន(K.២៣៥: D៨២, ៨៣, ៨៥, ១១៣ & ១១៤); សិវលិង្គស្ដុកឈូកលើ(K.២៩២: B២២); ព្រះគម្តែងអញសិវលិង្គ(នៅឯ)រុទ្របទ (K.៣៥២: S២០-២១); ព្រះសិវលិង្គភ្នំថ្ងៃ(K.៥១៨: D២៤&២៧) ។ល។

[៥] ស្រីនរេន្ទ្រគ្រាម ក្លាយមកជា នរិន្ទ ដែលសល់ឈ្មោះក្នុងព្រៃកនរិន្ទ ។

[៦] ពាក្យនេះសំដៅដល់ដីដែលគេចតឬចាត់ចែងរៀបចំជាទីមនុស្សរស់នៅ ។ បណ្ឌិត ឡុង សៀម (១៩៩៧) ពន្យល់ថា ចំណត (ចំនត/ចំនាត) គឺជាភូមិទើបបង្កើតថ្មី គឺភូមិទើបចាត់ចែងរៀបចំបង្កើតឡើងនោះឯង ។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

លោង ដែលខាងកើតមានប្រទល់ដល់ដីព្រះស្តៅប្រសព្វនឹងដីត្បូងរមាំង។ កាលពីឆ្នាំ ៩៧៩គ.ស. ព្រាហ្មណ៍សង្កស់និងមាធវៈ បានទិញដីបញ្ចូលក្នុងចំណតអទ្រើមលោងបន្ថែមទៀត ដែលដីនោះមានប្រទល់ខាងកើតប្រសព្វដីរបស់ប្រាសាទនៅត្បូងរមាំង។ តាមរយៈទិន្នន័យនេះយើងឃើញថា ដីអទ្រើមលោង ដែលក្រោយមកជាដីចំណុះឱ្យប្រាសាទស្តុកកក់ធំ គឺស្ថិតនៅខាងលិចត្បូងរមាំង។ តាមរយៈផែនទីពីលើអាកាស បង្ហាញឱ្យឃើញថាត្បូងរមាំងឬប្រាសាទបន្ទាយព្រាវនេះ ស្ថិតនៅចំទិសខាងកើតប្រាសាទស្តុកកក់ធំតែម្តង(សូមមើលបញ្ជីរូបភាព)។ ដីអទ្រើមលោងដែលមានប្រាសាទសិវលិង្គមួយផងនោះ ប្រហែលនៅចន្លោះតំបន់សំខាន់ទាំងពីរនេះជាក់ពុំខាន។ មានប្រាសាទពីរដែលគួរនឹងលើកយកមកពិចារណា គឺប្រាសាទល្បើកស្វាយ (IK៨៣២) និងប្រាសាទល្បើកអំពិល (IK៨៣៣)។ ប្រាសាទល្បើកស្វាយ មានតួប្រាសាទពីរសាងអំពីឥដ្ឋ មានកំពែងថ្មបាយក្រៀម និងកសិន្ធុទឹកមួយផង[៧] មានចម្ងាយ៦,៨០គីឡូម៉ែត្រពីប្រាសាទស្តុកកក់ធំ។ ប្រាសាទដែលមានតួប្រាង្គចំនួនពីរដូច្នេះ ច្រើនតែជាសាងឡើងឧទ្ទិសដល់ប្រាសាទព្រះនារាយណ៍[៨] ជាហេតុនាំឱ្យយើងយល់ថាទីនេះ ទំនងមិនមែនជាប្រាសាទសិវលិង្គ នៅអទ្រើមលោងនោះទេ។ ចំណែកឯប្រាសាទល្បើកអំពិលវិញ មានតួប្រាសាទមួយសាងអំពីឥដ្ឋ មានកសិន្ធុទឹកព័ទ្ធជុំវិញ មានកំពែងសាងពីថ្មបាយក្រៀម និងមានបារាយណ៍ទឹកមួយ[៩] មានចម្ងាយ១១គីឡូម៉ែត្រកន្លះពីប្រាសាទស្តុកកក់ធំ។ តួប្រាសាទជាឥដ្ឋបានបាក់បែកអស់ទៅហើយ ប៉ុន្តែនៅទីនោះយើងឃើញបល្ល័ង្កថ្មភក់ចំនួនមួយ នាគចែងប្រាសាទ និងវត្ថុសិល្បៈមួយចំនួនទៀតនៅក្នុងស.វ.ទី១១។ ប្រាសាទនេះមានលក្ខណៈជាប្រាសាទឧទ្ទិសដល់ព្រះឥសូរ ដែលគួរតែត្រូវនឹងប្រាសាទសិវលិង្គអទ្រើមលោង។ យើងឃើញថាដីអទ្រើមលោង

---

[៧] សូមមើល៖ https://cisark.mcfa.gov.kh/core/showsite.php?id=64, (Aymonier, 1901, p. 242) និង (Lunet, 1911, p. 412) ។

[៨] សូមអាន៖ សុខ កែវ សុវណ្ណារ៉ា (២០២០) *ទស្សនៈថ្មីលើប្រាសាទព្រះវិស្ណុ* ក្នុងអត្ថបទស្រាវជ្រាវថ្មីនិងគួរពិចារណា (លេខ២៣ ០១ សីហា ២០២០) តាមរយៈ https://www.facebook.com/media/set/?set=a.3461004050585036&type=3

[៩] សូមមើលនិងអាន៖ https://cisark.mcfa.gov.kh/core/showsite.php?id=65&keyword= , (Aymonier, 1901, p. 242) និង (Lunet, 1911, p. 412) ។

អត្ថបទដោយ៖ ហ៊ិន ឈុនតេង

គឺស្ថិតនៅខាងកើតប្រាសាទស្តុកកក់ធំនិងនៅខាងលិចប្រាសាទបន្ទាយព្រាវ។ ដីត្បូងរមាំង គឺស្ថិតនៅតំបន់ខាងកើតប្រាសាទស្តុកកក់ធំនិងប្រាសាទល្បើកអំពិល។ មកដល់ ចំណុចនេះ យើងសន្និដ្ឋានជាបឋមបានថា ត្បូងរមាំង គឺត្រូវនឹងតំបន់ប្រាសាទបន្ទាយព្រាវ។

តាមសិលាចារឹកប្រាសាទគោកពោធិ៍ (K.២៥៦/K.៨១៤) ត្បូងរមាំង គឺជាស្រុកមួយ ។ «ស្រុក» នៅសម័យអង្គរ គឺជាពាក្យសម្គាល់បំណែងចែកទឹកដីខាងរដ្ឋការ និងជាបច្ចេកពាក្យខាងភូមិសាស្ត្រ ដែលបញ្ជាក់នូវផ្នែកខាងរដ្ឋបាលតូចៗ ដែលមានអភិបាលរបស់ខ្លួន គឺមានប្រធានស្រុក ឬមានខ្លោញស្រុក។[10] ដូចដែលបានបញ្ជាក់កន្លងរួចមកហើយថា ប្រាសាទបន្ទាយព្រាវ គឺជាប្រាសាទសំខាន់និងមានទំហំជាងគេនៅតំបន់ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ។ ប្រាសាទនេះមានលក្ខណៈជាទីប្រជុំជនមានលក្ខណៈសក្តិសមជាស្រុកប្រាកដមែន ។

ចំណែកឯសិលាចារឹកប្រាសាទបឹង (K.៩៨៩) នៅឆ្នាំ១០០៨គ.ស. ព្រះបាទសូរ្យវម៌្មទេវទី១ ស្តេចបានចេញបញ្ជាឱ្យមន្ត្រីមួយក្រុមមាន កំស្តេងស្រីនរបតីន្ទ្រវម៌្ម កម្រតេងអញន្ទុបតីន្ទ្រលក្ស្មី ម្រតាញខ្លោញស្រីន្ទ្ទុបតីន្ទ្រាធិបតិវម៌្ម ម្រតាញខ្លោញស្រីន្ទ្ទុបតីន្ទ្រវម៌្ម ម្រតាញខ្លោញស្រីន្ទ្ទុបតីន្ទ្រាទិត្យ ម្រតាញខ្លោញស្រីកវីន្ទ្រោបកល្ប ឱ្យសាងសិលាចារឹកទុកនៅត្បូងរមាំង។ ផ្នែកដំបូងនៃសិលាចារឹកនេះ ចាររៀបរាប់អំពីប្រវត្តិរឿងរ៉ាវគ្រួសាររបស់ ស្តេងពៅ ចាប់តាំងពីរាជការរបស់ព្រះបាទជ័យវម៌្មទេវទី២ រហូតដល់ព្រះបាទសូរ្យវម៌្មទេវទី១។ បន្ទាប់មក គឺជាការរៀបរាប់អំពីការកសាងសិវលិង្គ ប្រតិមាផ្សេងៗ និងតង្វាយនានាចំពោះទេពទាំងនោះ។ តាមសេចក្តីរបស់សិលាចារឹកនេះ សិលាចារឹកដែលព្រះបាទសូរ្យវម៌្មទេវទី១ ទ្រង់ត្រាស់បង្គាប់ឱ្យក្រុមមន្ត្រីចារទុកនៅត្បូងរមាំងនោះ គឺត្រូវនឹងសិលាចារឹកប្រាសាទបឹង K.៩៨៩ នេះឯង ព្រោះកន្លងមក យើងពុំរកឃើញសិលាចារឹកព្រះបាទសូរ្យវម៌្មទី១ នៅប្រាសាទបន្ទាយព្រាវនោះឡើយ។ ប្រសិនបើទីតាំងប្រាសាទនេះ ត្រូវគ្នានឹងត្បូងរមាំងនោះ វាផ្ទុយនឹងព័ត៌មានដែលយើងបានពិនិត្យពីចំណុចខាងលើមក ហើយវាក៏បានក្លាយទៅជាចំណោទបញ្ហាចម្បងមួយ ក្នុងការស្វែងរកទីតាំងត្បូងរមាំងកាលពីបុរាណ។ វាក៏

[10] ឡុង សៀម, ១៩៩៧, ទំ. ២៤។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

ផ្ទុយនឹងទស្សនៈ លោក ហ្ស៊កក ហ្វ្រូលីយ៉េរ (1924) និងលោក ហ្ស៊កក សឺដែស (1954, p.165) ដែលយល់ថាត្បូងរមាំងដែលនិយាយក្នុងសិលាចារឹក K.៩៨៩ នេះ គឺជាឈ្មោះបុរាណរបស់ប្រាសាទបន្ទាយព្រាវ ។

ប្រាសាទបឹង ស្ថិតនៅទិសអាគ្នេយ៍ប្រាសាទស្តុកកក់ធំប្រមាណ៧៥ គីឡូម៉ែត្រ។ ចម្ងាយដ៏ឆ្ងាយនេះ មិនអាចឱ្យដីអន្ទើមលោងដែលចំណុះឱ្យប្រាសាទស្តុកកក់ធំនោះមានវិសាលភាពមកទល់នឹងដីរបស់ប្រាសាទបឹងនេះឡើយ ឬថាដីប្រាសាទបឹងនេះ ក៏មិនអាចមានវិសាលភាពឆ្ងាយមកទល់នឹងដីអន្ទើមលោងផងដែរ។ ប្រាសាទបឹងនេះ មានទំហំតូចល្មមប៉ុណ្ណោះ[១១] ពុំមានលក្ខណៈជាស្រុកដូចការបញ្ជាក់ក្នុងប្រាសាទគោកពោធិ៍នោះឡើយ។ មន្ត្រីសំខាន់នៅក្នុងការចារសិលាចារឹកប្រាសាទបឹង កសាងសិវលិង្គ ប្រតិមា និងធ្វើដង្វាយចំពោះទេពទាំងនោះ គឺ កំស្តែងស្រីនរបតិន្ទ្រវម៌្ម ដែលក្រោយមកឡើងជាព្រះគម្តែងអញស្រីនរបតិន្ទ្រវម៌្ម។ កំស្តែងស្រីនរបតិន្ទ្រវម៌្ម គឺជាបុត្រាមួយអង្គរបស់ព្រះបាទជ័យវម៌្មទី៤ ជាមួយព្រះគម្តែងអញនរបតីន្ទ្រទេវី ដែលមាននាមថាដើមថាស្តេញបិតព្រៅ ។ នៅក្នុងសិលាចារឹកប្រាសាទបន្ទាយព្រាវ (K.២២១ & K.២២២) តាមរយៈការធ្វើដង្វាយជាដី និងខ្ញុំបម្រើ ដែលមានមន្ត្រីចំណុះជាច្រើនបានផ្តល់អ្នកបម្រើដល់កំស្តែងថ្វាយដល់ប្រាសាទ យើងឃើញថាមន្ត្រីរូបនេះជាអ្នកមានអំណាចកាន់កាប់នាតំបន់ប្រាសាទនោះ ដែលបញ្ជាក់យ៉ាងច្បាស់ថានៅតំបន់ ត្បូងរមាំង ។ ដូច្នេះ ប្រាសាទបឹង ពុំអាចជា ត្បូងរមាំង នោះទេ។ យ៉ាងនេះក្តី សិលាចារឹក K.៩៨៩ ដែលព្រះមហាក្សត្រចាត់ឱ្យចារទុកនៅត្បូងរមាំងដែលត្រូវនឹងប្រាសាទបន្ទាយព្រាវនោះ បែរជារកឃើញនៅប្រាសាទបឹង គឺនៅជាបញ្ហាចោទនៅឡើយ។ យើងសង្ឃឹមថាចំណោទនេះ នឹងអាចដោះស្រាយបាននៅពេលខាងមុខពុំខាន។

ជាសរុបរួមមក ដោយផ្អែកតាមការពិភាក្សាខាងលើ យើងអាចសន្និដ្ឋានបានថាស្ថាននាម ត្បូងរមាំង កាលពីបុរាណ គឺត្រូវគ្នានឹងប្រាសាទបន្ទាយព្រាវ ដូចការយល់ឃើញរបស់លោកហ្ស៊កក ហ្វ្រូលីយ៉េរ និងលោក ហ្ស៊កក សឺដែស ពិតប្រាកដមែន។

[១១] សូមអានបន្ថែម៖ Aymonier (1901, p. 351) និង Lunet (1911, p. 360) ។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

## បញ្ជីរូបភាព



សំណៅផ្តិតសិលាចារឹកបន្ទាយព្រាវ (ដោយៈ ហ៊ុន ឈុនតេង)



ប្រាសាទល្បើកអំពិល (រូបថតៈ ចាន់ អឿន)



បល្ល័ង្កថ្មនៅប្រាសាទល្បើកស្វាយ (រូបថតៈ ចាន់ អឿន)

អត្ថបទដោយៈ ហ៊ុន ឈុនតេង



នាងថែងប្រាសាទល្បើកស្វាយ (រូបថត៖ ចាន់ អឿន)




ផែនទីតំបន់ប្រាសាទពាក់ព័ន្ធ (រូបថត៖ Google Earth)

# ឯកសារយោង

សុខ កែវ សុវណ្ណារ៉ា

(២០២០) ទស្សនៈថ្មីលើប្រាសាទព្រះវិស្ណុ ក្នុងអត្ថបទស្រាវជ្រាវថ្មីនិងគួរពិចារណា (លេខ ២៣ ០១ សីហា ២០២០) តាមរយៈ https://www.facebook.com/media/set/?set=a.3461004050585036&type=3

ឡុង សៀម

(១៩៩៧) ស្ពានទាមវិទ្យាខ្មែរ ពុទ្ធសាសនបណ្ឌិត្យ ពោធិ៍ពុម្ពខ្មែរអន្តរជាតិ ភ្នំពេញ

Aymonier, E.

(1901). Le Cambodge, Vol. II. EFEO.

Coedès, G.

(1951). Inscriptions du Cambodge (vol. III). Paris, Editions de Boccard.

Coedès, G.

(1954). Inscriptions du Cambodge (vol. VI). Paris, Editions de Boccard.

Groslier George.

(1924) Amarendrapura dans Amoghapura. In: Bulletin de l'Ecole française d'Extrême-Orient. Tome 24, 1924. pp.359-372

Jenner, P. N.

(2009). A dictionary of Angkorian Khmer. Pacific Linguistics, Research School of Pacific and Asian Studies, The Australian National University.

Lunet de Lajonquière, É.

(1911). Inventaire descriptif des monuments du Cambodge, Tome III. Paris: Imprimerie Nationale.

Pou, S.

(2004). Dictionnaire vieux khmer-français-anglais. Editions L'Harmattan.